# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ : ០០៧ គ.ជ.ប.ស.ណ.ន

# សេចក្តីណែនាំ
## ស្តីពី
## ការស្រង់ស្ថិតិប្រជាពលរដ្ឋ ប៉ាន់ស្មានអ្នកចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៨

**យោង ៖** -ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

-ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនិងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ

-សេចក្តីណែនាំរួមលេខ ០១១ សណន ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៥ ស្តីពីការរៀបចំត្រៀមបម្រើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ។

ក្នុងគោលបំណង កំណត់ឱ្យការស្រង់ស្ថិតិប្រជាពលរដ្ឋទទួលបានលទ្ធផលល្អ មានភាពត្រឹមត្រូវ មានភាពសុក្រឹត និងមានគណនេយ្យភាព ដើម្បីសម្រេចបានការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតមានភាពពេញលេញ ភាពត្រឹមត្រូវ និងបច្ចុប្បន្នភាពប្រកបដោយសុវត្ថិភាព គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមណែនាំលោក លោកស្រីប្រធាន លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោតទាំងអស់អនុវត្តការងារដូចខាងក្រោម ៖

១. សហការជាមួយអាជ្ញាធររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ ធ្វើការប្រមូលទិន្នន័យប្រជាពលរដ្ឋរួម អ្នកមានសិទ្ធិបោះឆ្នោត នៅតាមភូមិ ដើម្បីកំណត់ចំនួនអ្នកដែលត្រូវចុះឈ្មោះបោះឆ្នោត ចំនួននិងទីតាំងការិយាល័យបោះឆ្នោត និងការិយាល័យចុះឈ្មោះបោះឆ្នោត ។

២. សម្របសម្រួល និងណែនាំដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឱ្យយល់ដឹងអំពីខ្លឹមសារ និងគោលបំណងនៃការស្រង់ស្ថិតិសម្រាប់ការចុះឈ្មោះបោះឆ្នោត ។ ក្នុងការស្រង់ស្ថិតិប្រជាពលរដ្ឋ មេឃុំ ចៅសង្កាត់ និងស្មៀនឃុំ សង្កាត់ត្រូវចាត់ចែងអនុវត្តការងារតាមខ្លឹមសារខាងក្រោម ៖

២.១. ត្រូវសហការជាមួយនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់ និងមេភូមិដើម្បីបំពេញស្ថិតិប្រជាពលរដ្ឋថ្មីដាក់ក្នុងតារាងដែលផ្តល់ដោយ គ.ជ.ប (តារាងស្រង់ស្ថិតិប្រជាពលរដ្ឋសម្រាប់បំពេញដោយនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់) សម្រាប់បម្រើការចុះឈ្មោះបោះឆ្នោត ដោយអនុវត្តតាមការងារដូចខាងក្រោម ៖

**ក. ខ្ទង់ឈ្មោះភូមិ** ត្រូវពិនិត្យ និងកែតម្រូវអក្ខរាវិរុទ្ធឱ្យបានត្រឹមត្រូវតាមឈ្មោះភូមិជាក់ស្តែង ។ ចំពោះភូមិទើបបង្កើតថ្មី ឬភូមិឧបសម្ព័ន្ធ ដែលគ្មានឈ្មោះក្នុងតារាងត្រូវសរសេរបន្ថែម ទិន្នន័យផ្នែកខាងក្រោមនៃតារាង (ដូចខ្ទង់ឈ្មោះភូមិក្នុងតារាងខាងលើនៃទំព័រ) ដើម្បីងាយស្រួលកំណត់ចំនួន និងទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត ។

**ខ. ខ្ទង់ប្រជាពលរដ្ឋរួម** ត្រូវបំពេញចំនួនប្រជាពលរដ្ឋសរុបរួម គិតទាំងប្រជាពលរដ្ឋស្នាក់នៅអចិន្ត្រៃយ៍ និងប្រជាពលរដ្ឋស្នាក់នៅបណ្ដោះអាសន្ន ។

**គ. ខ្ទង់ប្រជាពលរដ្ឋអាយុ១៨ឆ្នាំឡើង** (បំបែកជា២ខ្ទង់)

-**សរុប** : ត្រូវបំពេញចំនួនប្រជាពលរដ្ឋសរុបទាំងប្រុស ទាំងស្រី គិតទាំងប្រជាពលរដ្ឋស្នាក់នៅអចិន្ត្រៃយ៍ និងស្នាក់នៅបណ្ដោះអាសន្ន ដែលមានអាយុ១៨ឆ្នាំឡើង (កើតមុន ឬត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០០១) ។

-**ស្រី** : ត្រូវបំពេញចំនួនប្រជាពលរដ្ឋភេទស្រីអាយុ ១៨ឆ្នាំឡើង គិតទាំងប្រជាពលរដ្ឋស្នាក់នៅអចិន្ត្រៃយ៍ និងប្រជាពលរដ្ឋស្នាក់នៅបណ្ដោះអាសន្ន ដែលមានអាយុ១៨ឆ្នាំឡើង(កើតមុន ឬត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០០១។

**ឃ. ខ្ទង់ប្រជាពលរដ្ឋ១៨ឆ្នាំឡើង** ក្រោយ គ.ជ.ប ប្រកាសផ្សាយបញ្ជីបោះឆ្នោតផ្លូវការ (បំបែកជា៧ខ្ទង់)

-**ខ្ទង់គ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ** ត្រូវស្រង់ចំនួនប្រជាពលរដ្ឋអាយុ១៨ឆ្នាំឡើង គិតទាំងស្នាក់នៅអចិន្ត្រៃយ៍ ទាំងស្នាក់នៅបណ្ដោះអាសន្ន ដែលមិនទាន់បានធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

-**ខ្ទង់ស្នាក់នៅបណ្ដោះអាសន្ន** ត្រូវស្រង់ចំនួនប្រជាពលរដ្ឋអាយុ១៨ឆ្នាំឡើង ទាំងប្រុស ទាំងស្រី ដែលមិនទាន់ចុះឈ្មោះបោះឆ្នោត និងផ្លាស់ទីលំនៅចូលមកស្នាក់នៅបណ្ដោះអាសន្នមានអាយុ ១៨ឆ្នាំឡើង (កើតមុន ឬត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០០១)។

-**ខ្ទង់មិនទាន់ចុះឈ្មោះបោះឆ្នោត** ត្រូវបំពេញចំនួនប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតចាប់ពីអាយុ ១៨ឆ្នាំឡើង ទាំងប្រុស ទាំងស្រី (កើតមុន ឬត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០០១) ដែលមិនទាន់បានចុះឈ្មោះបោះឆ្នោត ។

-**ខ្ទង់ផ្លាស់ចូល** ត្រូវបំពេញចំនួនប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោត (ទោះបីមានឬគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយក្ដី) ដែលបានផ្លាស់ទីលំនៅចូលមកពីឃុំ សង្កាត់ដទៃ ។

-**ខ្ទង់ផ្លាស់ចេញ** ត្រូវបំពេញចំនួនប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដែលបានផ្លាស់ទីលំនៅចេញពីឃុំ សង្កាត់ ។

-**ខ្ទង់ដកសិទ្ធិ** ត្រូវបំពេញចំនួនប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយដែលត្រូវបាន គ.ជ.ប ដកហូតជាបណ្ដោះអាសន្ននូវសិទ្ធិបោះឆ្នោត ។

-**ខ្ទង់ស្លាប់** ត្រូវបំពេញចំនួនប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយដែលបានស្លាប់ ។

**ង.** ក្រោយពីបំពេញតារាងស្ថិតិបានត្រឹមត្រូវរួច នគរបាលប៉ុស្ដិ៍រដ្ឋបាលឃុំ សង្កាត់ ត្រូវចុះហត្ថលេខាបោះត្រា និងបញ្ជូនទៅមេឃុំ ចៅសង្កាត់ ។

២.២. បន្ទាប់ពីទទួលបានតារាងស្រង់ស្ថិតិ ពីនគរបាលប៉ុស្ដិ៍រដ្ឋបាលឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ត្រូវបំពេញក្នុងតារាងដែលផ្ដល់ឱ្យដោយ គ.ជ.ប (តារាងស្រង់ស្ថិតិប្រជា

ពលរដ្ឋសម្រាប់បំពេញដោយ មេឃុំ ចៅសង្កាត់) ដោយអនុវត្តតាមការងារដូចខាងក្រោម ៖

**ក. បំពេញឡើងវិញ** តាមទិន្នន័យដែលមានក្នុងតារាងស្រង់ស្ថិតិប្រជាពលរដ្ឋដែលបំពេញហើយ និងផ្តល់ជូនដោយនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់ ។

**ខ. ខ្ទង់ចំនួនការិយាល័យបោះឆ្នោត** ត្រូវកំណត់ដូចខាងក្រោម៖

**-ភូមិ ឬភូមិឧបសម្ព័ន្ធ** ១ (មួយ) ត្រូវបង្កើតការិយាល័យបោះឆ្នោត ១(មួយ) យ៉ាងតិច ដែលមានប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតយ៉ាងច្រើន ៧៥០ នាក់ លើកលែងតែក្នុងភូមិនោះមានប្រជាពលរដ្ឋដែលមានអាយុ ១៨ឆ្នាំឡើង តិចជាង ១០០ (មួយរយ) នាក់ ត្រូវបញ្ចូលក្នុងភូមិណាមួយក្នុងឃុំ សង្កាត់ជាមួយដែលនៅជិតភូមិនោះបំផុត ។

**-នៅក្នុងភូមិ** ១ (មួយ) បើមានប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតលើសពីចំនួន ៧៥០ នាក់ ត្រូវបង្កើតការិយាល័យបោះឆ្នោតចំនួន ២ (ពីរ) និងលើសពីនេះទៅតាមចំនួនជាក់ស្តែងនៃចំនួនអ្នកមានសិទ្ធិបោះឆ្នោត ។

**គ. ខ្ទង់ចំនួនឈ្មោះក្នុងបញ្ជីឆ្នាំ២០១៧** ជាទិន្នន័យសម្រាប់ផ្ទៀងផ្ទាត់ជាមួយស្ថិតិឆ្នាំ២០១៨ ។

**ឃ. ខ្ទង់ទីតាំងការិយាល័យបោះឆ្នោត** ត្រូវត្រួតពិនិត្យ និងកែតម្រូវអក្ខរាវិរុទ្ធឱ្យបានត្រឹមត្រូវទៅតាមឈ្មោះទីតាំងជាក់ស្តែង ចំពោះទីតាំងទើបនឹងបង្កើតថ្មី ត្រូវបំពេញឈ្មោះទីតាំងការិយាល័យបោះឆ្នោតតាមភូមិសាស្ត្រជាក់ស្តែង និងត្រូវជ្រើសយកទីសារធារណៈដូចជា សាលារៀន វត្តអារាម សាលាបុណ្យ ឬទីសាធារណៈ ក្បែរទីប្រជុំផ្ទះប្រជាពលរដ្ឋនៅក្នុងភូមិ ។ ករណីមានភូមិ ២ (ពីរ) ឬ ៣ (បី) ក្នុងឃុំ សង្កាត់តែមួយ ដែលមានព្រំប្រទល់ជាប់ជាមួយទីសាធារណៈតែមួយ ដូចជា សាលារៀន វត្តអារាម អាចជ្រើសរើសយកទីតាំងជាមួយគ្នា ។

**ង. ខ្ទង់ទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត** ត្រូវត្រួតពិនិត្យនិងកែតម្រូវអក្ខរាវិរុទ្ធឱ្យបានត្រឹមត្រូវទៅតាមឈ្មោះទីតាំងជាក់ស្តែង ចំពោះទីតាំងទើបនឹងបង្កើតថ្មី ត្រូវបំពេញឈ្មោះទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោតតាមភូមិសាស្ត្រជាក់ស្តែង និងត្រូវជ្រើសរើសយកសាលាឃុំ សង្កាត់ ឬទីសាធារណៈ ដូចជា សាលារៀន វត្តអារាម សាលាបុណ្យ ឬទីសាធារណៈក្នុងភូមិ ឬទីតាំងផ្សេងទៀត ដែលមានចរន្តអគ្គិសនីប្រើប្រាស់ ឬងាយស្រួលផ្គត់ផ្គង់ចរន្តអគ្គិសនី ។ ក្រៅពីទីតាំងនៅសាលាឃុំ សង្កាត់ ត្រូវកំណត់ទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោតផ្សេងទៀតតាមទីប្រមូលផ្តុំនៃភូមិក្នុងឃុំ សង្កាត់ ។

**ច.** ក្រោយពីបំពេញតារាងស្ថិតិបានត្រឹមត្រូវរួច មេឃុំ ចៅសង្កាត់ត្រូវចុះហត្ថលេខា បោះត្រា និងផ្ញើមក លធ.ខប ដោយភ្ជាប់មកជាមួយនូវតារាងស្រង់ស្ថិតិប្រជាពលរដ្ឋដែលបំពេញដោយនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់ដើម្បីពិនិត្យផ្ទៀងផ្ទាត់ ។

៣. បន្ទាប់ពីទទួលបានតារាងស្រង់ស្ថិតិពីនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់រួចហើយ សូមលោក លោកស្រីប្រធាន លធ.ខប ធ្វើរបាយការណ៍ និងផ្ញើតារាងស្ថិតិទាំងនេះមក គ.ជ.ប យ៉ាងយូរត្រឹមថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨ ។

ទទួលបានសេចក្តីណែនាំនេះ សូមលោក លោកស្រីប្រធាន លធ.ខប ចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព ។

ថ្ងៃអង្គារ ៤កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨
**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**ប្រធាន**

**ស៊ិក ប៊ុនហុក**

**ចម្លងជូន**
- ក្រសួងមហាផ្ទៃ
- សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
«ដើម្បីសហការ»
- គណបក្សនយោបាយ
«ដើម្បីជូនជ្រាប»
- ឯកសារ-កាលប្បវត្តិ